រោងចក្រ
កាន់តែប្រសើរ
នៅកម្ពុជា

# ព្រឹត្តិប័ត្រ

លេខ ១៣ ខែឧសភា ឆ្នាំ២០០៩

# ប្រធានកម្មវិធីការងារ*កាន់តែប្រសើរ*ជាសកល លោកស្រី រ៉ូស ហារី វិលត្រឡប់មកកាន់ប្រទេសកម្ពុជា


*លោកស្រី រ៉ូស ហារី ប្រធានកម្មវិធីការងារកាន់តែប្រសើរជាសកល និយាយពីរបៀបដែលរោងចក្រកាន់តែប្រសើរនឹងតម្រង់ទិសដៅការងារដូចការងារកាន់តែប្រសើរជាសកល*

លោកស្រី រ៉ូស ហារី ដែលជាអតីតអ្នកគ្រប់គ្រងកម្មវិធី*រោងចក្រកាន់តែប្រសើរនៅកម្ពុជា* នៃអង្គការពលកម្មអន្តរជាតិ (ILO BFC) បានវិលត្រឡប់មកកាន់ប្រទេសកម្ពុជានៅក្នុងខែធ្នូ ដើម្បីជួយបង្កើតយុទ្ធសាស្ត្រអន្តរកាលរបស់កម្មវិធីនេះសម្រាប់ការពង្រីកសេវាកម្មក្នុងឧស្សាហកម្ម។

លោកស្រី ហារី បានចំណាយពេល ៣ ឆ្នាំ នៅក្នុងប្រទេសកម្ពុជា និងបានជួយបង្កើតវិធីសាស្ត្ររបស់កម្មវិធី ដើម្បីរួមបញ្ចូលការកសាងសមត្ថភាព និងកម្មវិធីបណ្តុះបណ្តាលជារួម។ លោកស្រីក៏បានដឹកនាំកិច្ចខិតខំប្រឹងប្រែងដើម្បីបង្កើតប្រព័ន្ធកុំព្យូទ័រសម្រាប់ការងារពិនិត្យឃ្លាំមើលលក្ខខណ្ឌការងារ និងធ្វើឱ្យការងារនេះមានលក្ខណៈជាប្រព័ន្ធថែមទៀតផង។ កិច្ចខិតខំប្រឹងប្រែងទាំងនេះបង្កើតឱ្យមានប្រព័ន្ធគ្រប់គ្រងព័ត៌មាន (IMS) របស់*រោងចក្រកាន់តែប្រសើរនៅកម្ពុជា* ដែលមានតួនាទីជាអន្តរការីរវាងរោងចក្រ និងអ្នកបញ្ជាទិញ ទទួលបានព័ត៌មានអំពីការពិនិត្យឃ្លាំមើលនេះ។ បច្ចុប្បន្នលោកស្រី ហារី ទទួលខុសត្រូវគ្រប់គ្រងកម្មវិធី*ការងារកាន់តែប្រសើរ*ជាសកល ដែលបង្កើតឡើងតាមគំរូរបស់*រោងចក្រកាន់តែប្រសើរនៅកម្ពុជា*។ កម្មវិធី*ការងារកាន់តែប្រសើរ* គឺជាសហប្រតិបត្តិការរវាងអង្គការពលកម្មអន្តរជាតិ និងសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC)។

កម្មវិធី*ការងារកាន់តែប្រសើរ* ប្រើប្រាស់វិធីសាស្ត្ររួមដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ដើម្បីឆ្លើយតបទៅនឹងលក្ខខណ្ឌការងារ និងសមត្ថភាពប្រកួតប្រជែងនៅក្នុងប្រព័ន្ធផ្គត់ផ្គង់សកល។ ការវាយតំលៃសហគ្រាស និងសេវាផ្តល់ប្រឹក្សាមានទំនាក់ទំនងជាមួយគ្នាទៅវិញទៅមក និងមានមូលដ្ឋានលើបទដ្ឋានវាយតំលៃសហគ្រាសសកលរួមមួយ ដែលត្រូវបានបង្កើតឡើងជុំវិញបទដ្ឋានការងារអន្តរជាតិ និងបទដ្ឋានល្អបំផុតរបស់ឧស្សាហកម្មស្តីពីការកែលំអ និងការបង្កើនកម្រិតរបស់សហគ្រាស។

ការបង្កើតបទដ្ឋានទាំងនេះ តម្រូវឱ្យក្រុមអ្នកបញ្ជាទិញអន្តរជាតិ ធ្វើការងារជាមួយនឹងកម្មវិធី*ការងារកាន់តែប្រសើរ* ដើម្បីធានាឱ្យបទដ្ឋានទាំងនេះស្របគ្នាជាមួយនឹងអាជីវកម្ម និងតម្រូវការអនុលោមតាមច្បាប់របស់អ្នកបញ្ជាទិញ។

ស្រដៀងគ្នានេះដែរ គំនិតយោបល់នានាត្រូវបានស្វែងរក និងទទួលបានពីក្រុមកម្មករនិយោជិត និងនិយោជកអន្តរជាតិដើម្បីខិតខំឱ្យមានតុល្យភាពល្អប្រសើររវាងការការពារកម្មករនិយោជិត និងសមត្ថភាពប្រកួតប្រជែងរបស់ឧស្សាហកម្ម។

*រោងចក្រកាន់តែប្រសើរនៅកម្ពុជា* កំពុងស្ថិតនៅក្នុងដំណើរការតម្រង់ទិសប្រតិបត្តិការរបស់ខ្លួនឱ្យស្របជាមួយនឹងកម្មវិធី*ការងារកាន់តែប្រសើរ*ជាសកល ដើម្បីឱ្យ*រោងចក្រកាន់តែប្រសើរ* អាចទទួលបានការគាំទ្របច្ចេកទេសល្អបំផុតដែលមានស្រាប់ក្នុងពេលជាមួយគ្នា កម្មវិធីនេះអាចបន្តកែលំអ និងពង្រីកសេវាកម្មរបស់ខ្លួនទៅដល់ឧស្សាហកម្មកាត់ដេរកម្ពុជា។

*រោងចក្រកាន់តែប្រសើរនៅកម្ពុជា* បានសម្ភាសន៍លោកស្រី ហារី នៅក្នុងដំណើរទស្សនៈកិច្ចរបស់លោកស្រីមកកាន់ប្រទេសកម្ពុជា ដើម្បីពិនិត្យទិសដៅរបស់កម្មវិធី និងចង់ដឹងពីអត្ថប្រយោជន៍អ្វីខ្លះដែល*រោងចក្រកាន់តែប្រសើរនៅកម្ពុជា* នឹងទទួលបានក្នុងនាមជាសមាជិករបស់ក្រុមកម្មវិធី*ការងារកាន់តែប្រសើរ*ប្រចាំប្រទេស។

***រោងចក្រកាន់តែប្រសើរ:*** បើតាមទស្សនៈរបស់លោកស្រី តើអ្នកដែលមានការពាក់ព័ន្ធនឹងរក្សាការជឿទុកចិត្តរបស់ពួកគេមកលើកម្មវិធី*រោងចក្រកាន់តែប្រសើរនៅកម្ពុជា* ដែរឬទេចំពោះឯករាជ្យភាព តម្លាភាព និង គុណភាពខ្ពស់របស់ការងារនៅពេលដែលកម្មវិធីនេះតម្រង់ទិសដៅស្របគ្នាជាមួយនឹងកម្មវិធី*ការងារកាន់តែប្រសើរ*?

***រ៉ូស ហារី:*** ខ្ញុំគិតថា ការជឿទុកចិត្តនឹងមានកាន់តែខ្លាំងជាងមុន ព្រោះ*ការងារកាន់តែប្រសើរ* គឺជាកម្មវិធីជាសកលមួយ ដែលទទួលបានការគាំទ្រយ៉ាងខ្លាំងក្លាពី ILO និង IFC។ ជានិច្ចជាកាល ប្រទេសកម្ពុជានឹងមានឋានៈពិសេសមួយនៅក្នុង*ការងារកាន់តែប្រសើរ* ដោយសារតែវាហាក់បីដូចជាបងប្អូនចំណាស់ជាងគេនៅក្នុងគ្រួសារមួយអញ្ចឹង។ គំនិតជាច្រើនសម្រាប់*ការងារកាន់តែប្រសើរ* បានយកចេញពី*រោងចក្រកាន់តែប្រសើរ*។ ប្រទេសកម្ពុជាមានបទពិសោធន៍ និងជំនាញយ៉ាងយូរនៅក្នុងផ្នែកនេះ ហើយខ្ញុំគិតថា ប្រទេសកម្ពុជានឹងបន្តក្លាយជាប្រទេសនាំមុខគេនៅក្នុងសកលលោក។ គុណសម្បត្តិនៃការមានកម្មវិធីជាសកលធំដូច្នេះ គឺយើងមានសមត្ថភាពវិនិយោគលើប្រព័ន្ធ និង ការបណ្តុះបណ្តាលបុគ្គលិក និងធានាឱ្យមានការគាំទ្រក្នុងកម្រិតមួយខ្ពស់។

***រោងចក្រកាន់តែប្រសើរ:*** តើកម្មវិធីនានា ដូចជា *រោងចក្រកាន់តែប្រសើរ* និង*ការងារកាន់តែប្រសើរ* អាចជួយកាត់បន្ថយផលប៉ះពាល់របស់វិបត្តិហិរញ្ញវត្ថុសកលលោកបានដែរឬទេ?

***រ៉ូស ហារី:*** វិបត្តិហិរញ្ញវត្ថុសកលកំពុងមានផលប៉ះពាល់មកលើប្រទេសជាច្រើននៅក្នុងពិភពលោក មិនមែនត្រឹមតែប្រទេសកម្ពុជានោះទេ។ មនុស្សកំពុងបាត់បង់ការងារ ហើយរោងចក្រកំពុងជួបប្រទះនឹងបញ្ហា។ *រោងចក្រកាន់តែប្រសើរ*មានកេរ្តិ៍ឈ្មោះជាសកល ដោយសារបានប្រើប្រាស់វិធីសាស្ត្រសាមញ្ញ ដើម្បីកែលំអបទដ្ឋានការងារ និងបង្កើនភាពប្រកួតប្រជែង ហើយប្រទេសកម្ពុជានៅតែមានឱកាសប្រើប្រាស់កេរ្តិ៍ឈ្មោះ បទដ្ឋានការងារល្អរបស់ខ្លួន។ អ្វីដែលយើងបានឮពីអ្នកបញ្ជាទិញអន្តរជាតិនោះគឺថា ប្រទេសកម្ពុជាមានអនាគតយ៉ាងត្រចះត្រចង់មួយ។ ហានិភ័យធំបំផុត គឺកង្វះខាតការគាំទ្ររឹងមាំដល់*រោងចក្រកាន់តែប្រសើរ* ជាពិសេសពីរោងចក្រ។ នៅក្នុងការសិក្សាមួយអំពីការយល់ឃើញរបស់អ្នកបញ្ជាទិញអំពីអនាគតរបស់ឧស្សាហកម្ម អ្នកបញ្ជាទិញពីប្រទេសកម្ពុជាបានកំណត់ហានីភ័យធំបំផុតសម្រាប់ប្រទេសកម្ពុជា គឺរោងចក្រមិនបានគាំទ្រគំនិតផ្តួចផ្តើម*រោងចក្រកាន់តែប្រសើរ*ឱ្យបានខ្លាំងក្លាគ្រប់គ្រាន់។ ខ្ញុំគិតថា អ្នកបញ្ជាទិញមានតួនាទីសំខាន់ ដែលត្រូវបំពេញពាក់ព័ន្ធជាមួយនឹងការបង្កើតការប្តេជ្ញាចិត្តចំពោះប្រទេសកម្ពុជា និងចំពោះកម្មវិធី និង ការបន្តបញ្ជាទិញពីប្រទេសនេះ សូម្បីតែនៅក្នុងស្ថានភាពមិនល្អក៏ដោយ ។

# ទស្សនៈរបស់ធនាគារពិភពលោក ជុំវិញវិបត្តិនៅក្នុងវិស័យកាត់ដេររបស់ប្រទេសកម្ពុជា

***បទសម្ភាសន៍ជាមួយលោក ស្តេហ្វាន ហ្គីមប៊ើត (Stéphane Guimbert) សេដ្ឋវិទូជាន់ខ្ពស់របស់ធនាគារពិភពលោក***


*លោក ស្តេហ្វាន ហ្គីមប៊ើត (Stéphane Guimbert) សេដ្ឋវិទូជាន់ខ្ពស់របស់ធនាគារពិភពលោក*

***រោងចក្រកាន់តែប្រសើរ:*** តើមានអ្វីកើតឡើងខ្លះពាក់ព័ន្ធនឹងកំណើន នៅក្នុងឧស្សាហកម្មកាត់ដេរកម្ពុជា?

***ស្តេហ្វាន ហ្គីមប៊ើត:*** កំណើនការនាំចេញសំលៀកបំពាក់ប្រចាំឆ្នាំបានធ្លាក់ចុះ ពីកំណើនពីរខ្ទង់រហូតដល់ចុងឆ្នាំ ២០០៧ មកត្រឹម -៨% នៅក្នុងខែមិនា ឆ្នាំ ២០០៩។ ដូច្នេះ មានភាពមិនប្រាកដប្រជាច្រើនអំពីផលប៉ះពាល់មកលើឧស្សាហកម្មកាត់ដេរកម្ពុជា។ មានការព្រួយបារម្ភថាអត្រាកំណើនការនាំចូលពីប្រទេសកម្ពុជាទៅកាន់ទីផ្សារសហរដ្ឋអាមេរិក នឹងអវិជ្ជមាន ខណៈពេលដែលអត្រាកំណើនរបស់គូប្រកួតប្រជែងដូចជាប្រទេសបង់ក្លាដេស និងវៀតណាម នៅតែវិជ្ជមានដដែល។

***រោងចក្រកាន់តែប្រសើរ:*** តើកន្លងមកមានផលប៉ះពាល់អ្វីខ្លះមកលើឧស្សាហកម្មកាត់ដេរកម្ពុជា និងជាពិសេសមកលើប្រជាជនក្រីក្រ និងងាយរងគ្រោះ?

***ស្តេហ្វាន ហ្គីមប៊ើត:*** វិស័យកាត់ដេរ បានឆ្លើយតបរួចហើយជាមួយនឹងការបិទរោងចក្រជាច្រើន ការបញ្ឈប់ការងារកម្មករនិយោជិត (យ៉ាងហោចណាស់ចំនួន ៦៣ ០០០ នាក់ ដកចំនួនការងារថ្មី ដែលត្រូវបានបង្កើតឡើងនៅតាមរោងចក្រថ្មីៗមួយចំនួនតូច) និង ការកាត់បន្ថយប្រាក់ឈ្នួលសម្រាប់ការងារបន្ថែមម៉ោង។ ផលប៉ះពាល់មានច្រើន តាមរយៈផលប៉ះពាល់មកលើទីផ្សារការងារ និងការបញ្ជូនប្រាក់ត្រឡប់ទៅស្រុកកំណើតវិញ។ មានពលករថ្មីចំនួន ២៥០ ០០០ នាក់ ចូលមកក្នុងទីផ្សារការងារជារៀងរាល់ឆ្នាំ។ ជាមួយនឹងការបាត់បង់ការងារនៅក្នុងឧស្សាហកម្មកាត់ដេរ និងសំណង់នេះនឹងបង្កើតឱ្យមានបញ្ហាប្រឈមធំមួយសម្រាប់ការងារនៅក្នុងឆ្នាំ ២០០៩។

ប៉ុន្តែ សំខាន់ត្រូវកត់សម្គាល់ថាវិស័យកសិកម្ម និងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធដែលជាវិស័យធំ នឹងបន្តដើរតួនាទីជាបណ្តាញសុវត្ថិភាព និងអាចស្រូបយកកម្លាំងពលកម្មមួយចំនួន។ លើសពីនេះទៅទៀតនៅក្នុងប្រទេសកម្ពុជា ក៏ដូចជានៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ទាំងអស់ផងដែរ អត្រាអត់ការងារធ្វើនៅមានកម្រិតទាប ព្រោះអ្នកដែលគ្មានការងារធ្វើ នឹងមិនអាចរស់ដោយគ្មានចំណូលបានឡើយ។ ផ្ទុយទៅវិញអ្វីដែលទំនងជានឹងកើតមានឡើង គឺបាតុភូត «អ្នកធ្វើការក្រីក្រ» ដែលជាអ្នកស្វែងរកសកម្មភាពមួយ ដើម្បីចិញ្ចឹមជីវិត ប៉ុន្តែនៅតែបន្តរស់ក្រោមបន្ទាត់នៃភាពក្រីក្រ ឬ គ្មានឱកាសកែលំអជីវភាពរស់នៅរបស់ពួកគេ។

យុទ្ធសាស្ត្រសម្រាប់ដោះស្រាយដទៃទៀត រួមមាន ការកាត់បន្ថយការប្រើប្រាស់ ដូចជា ពេលខ្លះញ៉ាំអាហារដែលមិនសូវមានជីវជាតិ ដូចដែលបានរកឃើញនៅក្នុងការសិក្សាថ្មីៗនេះ នៅក្នុងប្រទេសកម្ពុជា ឬ ការលក់ទ្រព្យសម្បត្តិ។ ទាំងនេះគឺជាការព្រួយបារម្ភរបស់យើង ដោយសារតែផលប៉ះពាល់នេះមិនមែនគ្រាន់តែជាផលប៉ះពាល់ភ្លាមៗប៉ុណ្ណោះទេ ថែមទាំងជាផលប៉ះពាល់ដល់ជីវភាពរស់នៅរបស់ប្រជាជនខ្មែរទាំងនេះ និងគ្រួសាររបស់ពួកគេនាពេលអនាគតថែមទៀតផង។

***រោងចក្រកាន់តែប្រសើរ:*** តើធនាគារពិភពលោកកំពុងធ្វើអ្វីខ្លះដើម្បីឆ្លើយតបទៅនឹងស្ថានភាពនេះ នៅក្នុងឧស្សាហកម្មកាត់ដេរ និងនៅក្នុងស្ថានភាពទូទៅ?

***ស្តេហ្វាន ហ្គីមប៊ើត:*** យើងបាន និងកំពុងធ្វើការងារយ៉ាងសកម្មជាមួយរដ្ឋាភិបាល ដើម្បីស្វែងយល់ឱ្យកាន់តែប្រសើរអំពីស្ថានភាពនេះ និងផ្តល់ការគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលនៅក្នុងវិស័យជាច្រើន។ ការឆ្លើយតបរបស់រដ្ឋាភិបាលមានច្រើនយ៉ាង ចាប់ពីគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច រហូតដល់បញ្ហាក្នុងវិស័យហិរញ្ញវត្ថុ និងចាប់ពីហេដ្ឋារចនាសម្ព័ន្ធជនបទ ដល់បញ្ហាបរិយាកាសធុរកិច្ច។ អ្វីដែលគួរឱ្យកត់សម្គាល់នោះ គឺការគាំទ្ររបស់ធនាគារពិភពលោក ចំពោះការឆ្លើយតបក្នុងវិស័យកសិកម្ម និងបណ្តាញសុវត្ថិភាពសង្គមតាមរយៈប្រតិបត្តិការថ្មីមួយ ដែលមានទឹកប្រាក់ ១៣ លានដុល្លា ដែលនឹងត្រូវសម្រេច នៅក្នុងសប្តាហ៍ខាងមុខនេះ។ យើងក៏កំពុងគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាល នៅក្នុងការងារសំរួលពាណិជ្ជកម្ម ក៏ដូចជាផ្តល់ការគាំទ្រដល់វិស័យកាត់ដេរតាមរយៈការគាំទ្រជាហិរញ្ញវត្ថុរបស់យើងដល់*រោងចក្រកាន់តែប្រសើរនៅកម្ពុជា*។ សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ(IFC) ក៏កំពុងផ្តល់ជំនួយបច្ចេកទេសដល់ការបង្កើតយុទ្ធសាស្ត្ររយៈពេលមធ្យមសម្រាប់*រោងចក្រកាន់តែប្រសើរ*ផងដែរ។

# សម្រង់ព័ត៌មាន

**«ត្រង់ទៅកាន់ប្រភព» កាសែតទីភ្នំពេញប៉ុស្តិ៍ _ ៦ កុម្ភៈ ២០០៩**

កិច្ចសម្ភាសន៍ជាមួយនឹងអ្នកនិពន្ធដើមកំណើតនៅអូហាយអូ លោកឃែលស៊ី ធីមើមែន (Kelsey Timmerman) រំឭកឡើងវិញនូវបទពិសោធន៍របស់លោក នៅពេលលោកចំណាយពេល១ខែ នៅក្នុងប្រទេសកម្ពុជា ជាផ្នែកមួយនៃដំណើរទស្សនៈកិច្ចជាសកលរបស់លោក ដើម្បីស្វែងយល់ពីប្រភពនៃសំលៀកបំពាក់ដែលលោកចូលចិត្ត (ដូចជា ចិន ហុងឌុយរ៉ាស់ និង បង់ក្លាដេស)។ អ្នកនិពន្ធរូបនេះបាននិយាយថា ឧស្សាហកម្មកាត់ដេរកម្ពុជា គឺជាឧស្សាហកម្មល្អជាងគេមួយនៅក្នុងពិភពលោក ខាងបទដ្ឋានការងារមួយផ្នែកដោយសារតែកម្មវិធី*រោងចក្រកាន់តែប្រសើរ* នៃអង្គការពលកម្មអន្តរជាតិដែលជាកម្មវិធីពិនិត្យឃ្លាំមើលលក្ខខណ្ឌការងារ។

**«វេទិកាបានប្រាប់ថា ចាំបាច់ត្រូវមានកំណែទម្រង់ដើម្បីដោះស្រាយវិបត្តិ» ទីខេមបូឌាដេលី _ ៦ កុម្ភៈ ២០០៩**

អត្ថបទនេះរំឭកឡើងវិញដោយសង្ខេបអំពីស្ថានភាពបច្ចុប្បន្នរបស់សេដ្ឋកិច្ច ជាពិសេស ឧស្សាហកម្មកាត់ដេរ ដោយប្រើប្រាស់របាយការណ៍របស់ធនាគារពិភពលោក ដែលត្រូវបានរៀបរៀងឡើងសម្រាប់វេទិកាសេដ្ឋកិច្ចកម្ពុជាប្រចាំឆ្នាំ លើកទី ៣។ របាយការណ៍នេះ លើកទឹកចិត្តឱ្យរដ្ឋាភិបាលប្រើប្រាស់បទពិសោធន៍របស់*រោងចក្រកាន់តែប្រសើរនៅកម្ពុជា* នៅក្នុងវិស័យដទៃទៀត។

**«របៀបដែល*ការងារកាន់តែប្រសើរ* ធ្វើឱ្យមានអ្នកបញ្ជាទិញកាន់តែប្រសើរ» BSR ប្រចាំសប្តាហ៍ វ៉ុល ១២ លេខ ១៤ _ ១៣ មេសា ២០០៩**

នៅក្នុងអត្ថបទនេះ *រោងចក្រកាន់តែប្រសើរនៅកម្ពុជា* និង *ការងារកាន់តែប្រសើរវៀតណាម* ត្រូវបានកំណត់ និងលើកមកបង្ហាញថាជាកម្មវិធីសំខាន់ៗដែលធ្វើការកែលំអលក្ខខណ្ឌការងារ និងបង្កើនសមត្ថភាពប្រកួតប្រជែងរបស់ឧស្សាហកម្ម។ អត្ថបទនេះកត់សម្គាល់ពីភាពចាំបាច់ដ៏សំខាន់ដើម្បីឱ្យមានការសហការគ្នារវាងរោងចក្រ និងអ្នកបញ្ជាទិញ សំដៅបន្តធ្វើការងារ កែលំអបទដ្ឋានការងារ ចំពេលដែលកំពុងមានវិបត្តិនៅក្នុងវិស័យឧស្សាហកម្មកាត់ដេរបច្ចុប្បន្ន។

**«ការនាំចេញសំលៀកបំពាក់របស់កម្ពុជា មានការធ្លាក់ចុះ នៅពេលដែលតម្រូវការមានការថយចុះក្នុងសហរដ្ឋអាមេរិក និងអឺរ៉ុប» Bloomberg _ ១៨ មីនា ២០០៩**

Bloomberg បានរាយការណ៍ថា កំណើននៃឧស្សាហកម្មកាត់ដេរកម្ពុជា នៅក្នុងកំឡុងទសវត្សរ៍ចុងក្រោយនេះកើតឡើង ដោយសារតែប្រទេសនេះមានកេរ្តិ៍ឈ្មោះល្អខាងបទដ្ឋានការងារ ដូចដែលបានពិនិត្យឃ្លាំមើលដោយ*រោងចក្រកាន់តែប្រសើរនៅកម្ពុជា*នៃអង្គការពលកម្មអន្តរជាតិ។
http://www.bloomberg.com/apps/news?pid=20601087&sid=a8a_0C6ckTjs&refer=home

# វិបត្តិហិរញ្ញវត្ថុសកល មានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរមកលើកម្មករនិយោជិតក្នុងវិស័យឧស្សាហកម្មកាត់ដេរកម្ពុជា


*កម្មការនីកាត់ដេរវ័យក្មេងម្នាក់កំពុងត្រួតពិនិត្យគុណភាពសំលៀកបំពាក់ នៅកន្លែងធ្វើការរបស់នាង*

វិបត្តិស្បៀងអាហារ និងប្រេងឥន្ធនៈសកលកាលពីឆ្នាំមុន មានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរមកលើប្រជាជនកម្ពុជា ជាពិសេសប្រជាជនក្រីក្រ និងងាយរងគ្រោះ។ ការកើនឡើងយ៉ាងខ្លាំងនូវតំលៃទំនិញ មានន័យថាកម្មករនិយោជិតរោងចក្រកាត់ដេរក្នុងប្រទេសកម្ពុជា ដែលជាសសៃឈាមធ្វើឱ្យសេដ្ឋកិច្ចរបស់ប្រទេសមានដំណើរការ ជួបប្រទះនឹងបញ្ហាប្រឈមបន្ថែមសម្រាប់បំពេញតម្រូវការជីវភាពរបស់ពួកគេ។ កម្មករនិយោជិតភាគច្រើនគឺជាស្ត្រី ហើយភាគច្រើនទទួលបានកម្រៃតិចជាង ១០០ ដុល្លា ក្នុងមួយខែ។ កម្មករនិយោជិតទាំងនេះបង្ហាញពីការព្រួយបារម្ភរបស់ពួកគេ ថាតើត្រូវបន្តរស់នៅក្នុងបរិយាកាសបែបនេះដោយរបៀបណា ខណៈពេលដែលពួកគេត្រូវបញ្ជូនប្រាក់កាសខ្លះទៅកាន់ស្រុកកំណើត ដើម្បីជួយទ្រទ្រង់ជីវិភាពគ្រួសារដែលជួបការលំបាកនៅឯជនបទ ហើយក្នុងពេលជាមួយគ្នាត្រូវរកប្រាក់ឱ្យបានគ្រប់គ្រាន់ ដើម្បីរ៉ាប់រងការចំណាយលើម្ហូបអាហារ និងថ្លៃឈ្នួលផ្ទះស្នាក់នៅ។

ក្រោយពីស្ថានភាពដ៏លំបាកកាលពីឆ្នាំទៅ ប្រទេសកម្ពុជាសព្វថ្ងៃកំពុងជួបប្រទះនឹងឱនភាពសេដ្ឋកិច្ច។ កាលពីពេលថ្មីៗនេះ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានមានប្រសាសន៍ជាលើកទី ១ ថា សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាមិនអាចជៀសផុតពីវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុសកលនេះបានឡើយ។

សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា នៅក្នុងបណ្តាឆ្នាំកន្លងទៅនេះ មានការរីកចំរើនយ៉ាងខ្លាំង ដោយបានធ្វើឱ្យកំណើនផលទុនក្នុងស្រុកសរុប (GDP) សម្រាប់មនុស្សម្នាក់កើនឡើងទ្វេដងរវាងពីឆ្នាំ ១៩៩៨ ដល់ ២០០៧ ដែលកើតឡើងដោយសារស្ថិរភាពនយោបាយល្អ សមាហរណកម្មស៊ីជម្រៅចូលទៅក្នុងសកលលោក និងការពង្រឹងគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច។

ទោះជាយ៉ាងនេះក្តី កង្វះខាតភាពសំបូរបែបលើប្រភពចំណូល និងការពឹងអាស្រ័យរបស់ប្រទេសនេះលើវិស័យកាត់ដេរ ទេសចរណ៍ និងសំណង់ កំពុងដាក់សំពាធមកលើកំណើននេះ។ បច្ចុប្បន្ន ឧស្សាហកម្មទាំង៣ខាងលើ ជាពិសេសឧស្សាហកម្មកាត់ដេរ ដែលស្មើនឹង ១ ភាគ ៣ នៃការនាំចេញសរុបរបស់ប្រទេសកម្ពុជាកំពុងប្រឈមនឹងហានិភ័យ ធ្លាក់ចុះពីកំណើនដ៏ខ្ពស់កាលពី ២-៣ ឆ្នាំកន្លងទៅនេះ។ ប្រទេសអភិវឌ្ឍន៍ជាពិសេសសហរដ្ឋអាមេរិក បានធ្លាក់ចូលទៅក្នុងឱនភាពសេដ្ឋកិច្ច ហើយតម្រូវការខាងក្រៅមានការថយចុះ។ ប្រទេសកម្ពុជាពឹងអាស្រ័យខ្លាំងលើលំហូរទុនពីបរទេស ហើយនាពេលបច្ចុប្បន្ននេះ ការពឹងអាស្រ័យបែបនេះកំពុងប៉ះពាល់ដល់សេដ្ឋកិច្ចរបស់ខ្លួន ដោយសារតែវិបត្តិសេដ្ឋកិច្ចកំពុងកើតមាននៅក្នុងបណ្តាប្រទេសដែលជាទីផ្សាររបស់ប្រទេសនេះ។

លោក ស្តេហ្វាន ហ្គីមប៊ើត (Stéphane Guimbert) សេដ្ឋវិទូជាន់ខ្ពស់របស់ធនាគារពិភពលោក ប្រចាំនៅប្រទេសកម្ពុជា ដែលបានដឹកនាំក្រុមផលិតរបាយការណ៍របស់ធនាគារពិភពលោកស្តីពីការធានានិរន្តរភាពកំណើននៅក្នុងបរិយាកាសប្រកួតប្រជែងមានប្រសាសន៍ថា សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជានឹងមានការថយចុះដោយកំណើន GDP ត្រូវបានគេព្យាករណ៍ថានឹងមានអត្រា -១,០% ក្នុងឆ្នាំ ២០០៩។ ការនាំចេញសំលៀកបំពាក់បានធ្លាក់ចុះជិត ២០% នៅក្នុងរយៈពេល ២ ខែដំបូង នៃឆ្នាំ ២០០៩ បើប្រៀបនឹងរយៈពេលដូចគ្នានេះកាលពីឆ្នាំ ២០០៨ នេះបើតាមតួលេខពីក្រសួងពាណិជ្ជកម្ម។ ការនាំចេញទៅកាន់សហរដ្ឋអាមេរិកថយចុះជិត ៣០% មកត្រឹម ២៤០,១៦ លានដុល្លា។ ការនាំចេញទៅកាន់សហភាពអឺរ៉ុប (EU) ថយចុះប្រហែលជា ១២,២៨% មកត្រឹម ៨៩,១៨ លានដុល្លា។ ការនាំចេញទៅកាន់ប្រទេសកាណាដា ធ្លាក់ចុះចំនួន ៦,៥៧% មកត្រឹម ៣០,៨៦ លានដុល្លា។ ប៉ុន្តែ ការនាំចេញទៅកាន់ទីផ្សារដទៃទៀតបានកើនឡើងជិត ៦០% ដល់ ៤០,៨៦ លានដុល្លា។

ផលប៉ះពាល់កំពុងកើតមានក្នុងវិស័យនេះ ជាមួយនឹងភាពមិនប្រាកដប្រជា និងការបាត់បង់ការងារក្នុងទ្រង់ទ្រាយធំ : តួលេខចុងក្រោយបង្ហាញថាមានការងារចំនួន ៦៣ ០០០ ត្រូវបានបាត់បង់នៅក្នុងឧស្សាហកម្មដែលផ្តល់ការងារឱ្យប្រជាជនចំនួន ៣៥០ ០០០ នាក់ ហើយការងារចំនួន ១០០ ០០០ ទៀត

*សូមអានតទៅទំព័រទី ២*

# ផែនការសកម្មភាពសម្រាប់ប្រទេសកម្ពុជា : សមាជិករបស់អង្គការពលកម្មអន្តរជាតិពិភាក្សាគ្នាអំពីការឆ្លើយតបនៅក្នុងប្រទេសចំពោះវិបត្តិ


*បណ្ឌិត ស៊ូកទី ដាសហ្គុបតា (Sukti Dassgupta) អ្នកឯកទេសជាន់ខ្ពស់ខាងការងាររបស់អង្គការពលកម្មអន្តរជាតិ ថ្លែងសន្ទរកថាអំពីផែនការសកម្មភាពរបស់អង្គការពលកម្មអន្តរជាតិ ទៅកាន់អ្នកចូលរួម*

ជាផ្នែកមួយនៃការអបអរសាទរ ក៏ដូចជាព្រឹត្តិការណ៍ជុំវិញខួបលើកទី ៩០ នៃការបង្កើតអង្គការពលកម្មអន្តរជាតិ (ILO) កាលពីថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០០៩ អ្នកជំនាញ និងអ្នកដឹកនាំបានជួបជុំគ្នាពិភាក្សាពីរបៀបដែលសមាជិករបស់ ILO អាចឆ្លើយតបទៅនឹងវិបត្តិសកលដែលកំពុងកើតមាននៅក្នុងប្រទេសកម្ពុជា។ នាពេលបច្ចុប្បន្ននេះ វិបត្តិនេះកំពុងធ្វើឱ្យមានភាពជ្រួលច្របល់នៅក្នុងបណ្តាប្រទេសអភិវឌ្ឍន៍ ដោយសារផលប៉ះពាល់ផ្ទាល់របស់វិបត្តិនេះ ហើយនឹងមានផលប៉ះពាល់អវិជ្ជមានមកលើប្រទេសកំពុងអភិវឌ្ឍន៍ដូចជាប្រទេសកម្ពុជាទៅលើកំណើននៃការនាំចេញ និងការវិនិយោគដោយផ្ទាល់ពីបរទេស (FDI)។

ផែនការសកម្មភាពរបស់អង្គការ ILO សម្រាប់ប្រទេសកម្ពុជា ត្រូវបានបង្ហាញទៅកាន់អ្នកចូលរួមនៅក្នុងកិច្ចប្រជុំនេះ ដោយលោក ដេវីដ វីលៀម (David Williams) មន្ត្រីបច្ចេកទេសរបស់ ILO។ បទបង្ហាញនេះ បង្ហាញពីទិដ្ឋភាពទូទៅនៃផលប៉ះពាល់របស់វិបត្តិហិរញ្ញវត្ថុ នៅក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ន ដោយប្រើប្រាស់ការវាយតំលៃជាបន្ទាន់របស់អង្គការ ILO ដែលធ្វើឡើងក្នុងពេលថ្មីៗនេះដោយវិទ្យាស្ថានកម្ពុជាដើម្បីសិក្សាការអភិវឌ្ឍន៍ (CIDS)។

ប្រទេសកម្ពុជានឹងមិនអាចរួចផុតពីផលប៉ះពាល់នៃវិបត្តិហិរញ្ញវត្ថុសកលនេះបានឡើយ។ ច្រកបញ្ជូនធំជាងគេ គឺការនាំចេញ និង FDI ដែលច្រកទាំង ២ នេះបានធ្លាក់ចុះយ៉ាងលឿននៅក្នុងរយៈពេលប៉ុន្មានខែចុងក្រោយនេះ។ ឧស្សាហកម្មកាត់ដេរ និងសំណង់ ដែលជាកម្លាំងចលករ ២ ក្នុងចំណោមកម្លាំងចលករជម្រុញកំណើនទាំង ៤ របស់ប្រទេសកម្ពុជា ទទួលរងផលប៉ះពាល់ជាងគេ។ ជាពិសេស ឧស្សាហកម្មកាត់ដេរនឹងទំនងជាមើលឃើញការខាតបង់ធ្ងន់ធ្ងរ ដែលធ្វើឱ្យមានការបញ្ឈប់ការងារ ដាក់បន្ទុកមិនសមាមាត្រដល់កម្មករនិយោជិតក្មេងៗ។ នៅពេលដែលការនាំចេញមានការធ្លាក់ចុះកំណើនសេដ្ឋកិច្ចក៏មានការធ្លាក់ចុះដែរ ហើយអាចបង្កើនភាពក្រីក្រ និងទុក្ខលំបាកវេទនាដល់ប្រជាជនកម្ពុជា។

ដើម្បីស្វែងយល់ និងអាចជួយដល់ការឆ្លើយតបចំពោះវិបត្តិនេះឱ្យប្រសើរ អង្គការពលកម្មអន្តរជាតិបានរៀបចំឱ្យមានការវាយតំលៃជាបន្ទាន់មួយដែលបានរៀបរាប់ខាងលើ (ក៏ដូចជាបានប្រកាសសម្ពោធក្នុងកិច្ចប្រជុំនេះ)។ ការិយាល័យប្រចាំអនុតំបន់ក្នុងទីក្រុងបាងកក បានរៀបចំឱ្យមានបេសកកម្មមួយមកកាន់ប្រទេសកម្ពុជា ដើម្បីពិភាក្សាអំពីស្ថានភាពនេះជាមួយនឹងរាជរដ្ឋាភិបាល អ្នកពាក់ព័ន្ធដទៃទៀត និងដៃគូអភិវឌ្ឍន៍ និងដើម្បី

*សូមអានតទៅទំព័រទី ២*

## ការវាយតំលៃជាបន្ទាន់ពីផលប៉ះពាល់នៃវិបត្តិហិរញ្ញវត្ថុលើប្រទេសកម្ពុជា

ដើម្បីជួយដល់អង្គការពលកម្មអន្តរជាតិ និងដៃគូពាក់ព័ន្ធទាំងអស់ឱ្យកាន់តែយល់ពីផលប៉ះពាល់នៃវិបត្តិហិរញ្ញវត្ថុ វិទ្យាស្ថានកម្ពុជាដើម្បីសិក្សាការអភិវឌ្ឍន៍ បានធ្វើការវាយតំលៃជាបន្ទាន់មួយដែលបង្ហាញពីវិស័យដែលទទួលផលប៉ះពាល់ខ្លាំងជាងគេ ដូចជាវិស័យវាយណភ័ណ្ឌ និងសំលៀកបំពាក់ សំណង់ ទេសចរណ៍ និងអចលនទ្រព្យ។

ដើម្បីកាត់បន្ថយផលប៉ះពាល់នេះ វិទ្យាស្ថានកម្ពុជាដើម្បីសិក្សាការអភិវឌ្ឍន៍ ផ្តល់យោបល់ឱ្យបង្កើតឡើងនូវប្រព័ន្ធផ្តល់ព័ត៌មានការងារ ដើម្បីជួយកម្មករនិយោជិតបាត់បង់ការងារ អាចស្វែងរកការងារ និងបង្កើតកម្មវិធីទីផ្សារការងារដើម្បីបង្កើនភាពអាចរកការងារបាន ដូចជាការបណ្តុះបណ្តាលជំនាញ។

របាយការណ៍នេះ ក៏បានបញ្ជាក់ពីតម្រូវការក្នុងការឈានទៅរកការបណ្តុះបណ្តាលវិជ្ជាជីវៈមួយដែលល្អប្រសើរ ដើម្បីឱ្យប្រទេសកម្ពុជាបន្តមានកំណើនទៅមុខ។




ព្រឹត្តិប័ត្រនេះ ត្រូវបានបោះពុម្ពផ្សាយដោយគំរោង*រោងចក្រកាន់តែប្រសើរនៅកម្ពុជា* នៃអង្គការពលកម្មអន្តរជាតិ ។
ទស្សនៈទាំងឡាយនៅក្នុងព្រឹត្តិប័ត្រនេះ មិនជាចាំបាច់ឆ្លុះបញ្ចាំងពីទស្សនៈជាផ្លូវការរបស់អង្គការពលកម្មអន្តរជាតិឡើយ ។
ផ្ទះលេខ ៩ ផ្លូវលេខ ៣២២ សង្កាត់បឹងកេងកងទី ១ ភ្នំពេញ កម្ពុជា _ ប្រអប់សំបុត្រលេខ ២៦៤២
ទូរស័ព្ទ: (៨៥៥_២៣) ២១២ ៨៤៧ លេខបន្ត ១០៦ _ ទូរសារ: (៨៥៥_២៣) ២១២ ៩០៣
សម្រាប់ការទទួលយកព្រឹត្តិប័ត្រអេឡិចត្រូនិច សូមចុះឈ្មោះតាមរយៈវិបសាយ www.betterfactories.org/ilo
សម្រាប់ចម្ងល់ផ្សេងៗ សូមទាក់ទងមកកាន់មន្ត្រីទំនាក់ទំនង តាមរយៈអ៊ីម៉េល betterfactories@ilo.org

better factories Cambodia

## ផ្នែកខាងក្នុង

អ្នកបញ្ជាទិញអន្តរជាតិ : វិបត្តិសេដ្ឋកិច្ចធ្វើឱ្យគំនិតផ្តួចផ្តើមដូច*រោងចក្រកាន់តែប្រសើរ*
កិច្ចប្រជុំតុមូលធុរកិច្ចរបស់អ្នកជំនាញសេដ្ឋកិច្ច ជាមួយរាជរដ្ឋាភិបាល
កម្រងអត្ថបទស្តីពីប្រវត្តិអ្នកពាក់ពន្ធ័សំខាន់ៗក្នុងវិស័យឧស្សាហកម្មកាត់ដេរ

# អ្នកបញ្ជាទិញអន្តរជាតិ : វិបត្តិសេដ្ឋកិច្ចធ្វើឲ្យគំនិតផ្តួចផ្តើម ដូច *រោងចក្រកាន់តែប្រសើរ* កាន់តែមានតំលៃជាងមុន

គំរោង *រោងចក្រកាន់តែប្រសើរនៅកម្ពុជា* និង *ការងារកាន់តែប្រសើរនៅវៀតណាម* បានចូលរួមវេទិការអ្នកបញ្ជាទិញ ដែលប្រារព្ធឡើងក្នុងទីក្រុងហុងកុង កាលពីថ្ងៃទី ២៦ និង ២៧ ខែមិនា ឆ្នាំ ២០០៩។ វេទិកានេះត្រូវបានរៀបចំឡើងដោយក្រុមហ៊ុន លី និង ហ្វុង និងមូលនិធិអភិវឌ្ឍន៍វិស័យឯកជនតំបន់មេគង្គនៃសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ។

អ្នកបញ្ជាទិញជាង ៤០ ក្រុមហ៊ុន និង អ្នកផ្គត់ផ្គង់ និងអ្នកលក់ធំៗជាង ២០ បានជួបពិភាក្សាពីរបៀបកែលំអលក្ខខណ្ឌការងារ និងភាពប្រកួតប្រជែងរបស់ឧស្សាហកម្មជាមួយនឹងការយកចិត្តទុកដាក់លើផលប៉ះពាល់ពីវិបត្តិសេដ្ឋកិច្ចថ្មីៗនេះ។

ចំនួនអ្នកបញ្ជាទិញដែលចូលរួមក្នុងវេទិកានេះ កើនឡើងជាបន្តបន្ទាប់ចាប់ពី *រោងចក្រកាន់តែប្រសើរ* បង្កើតវេទិកានេះឡើងក្នុងឆ្នាំ ២០០៥។ វេទិកានេះដំបូងឡើយគ្រាន់តែជាមធ្យោបាយមួយ ដើម្បីទទួលយកគំនិតយោបល់របស់អ្នកបញ្ជាទិញក្នុងការអភិវឌ្ឍន៍បន្ថែមទៀតដល់គំរោង *រោងចក្រកាន់តែប្រសើរ* ប៉ុន្តែពេលនេះបានក្លាយជាវេទិកាសម្រាប់ឧស្សាហកម្មទាំងមូល ដែលមានការពិភាក្សាពីបញ្ហាទាំងឡាយក្នុងឧស្សាហកម្ម រាប់បញ្ចូលពីទំនាក់ទំនងវិជ្ជាជីវៈរហូតដល់បរិយាកាសក្នុងឧស្សាហកម្មនេះ។

សារយ៉ាងសំខាន់លេចចេញពីវេទិកាអ្នកបញ្ជាទិញនៅទីក្រុងហុងកុងឆ្នាំនេះ គឺគំនិតផ្តួចផ្តើមដូចជា *រោងចក្រកាន់តែប្រសើរ* កាន់តែសំខាន់ខណៈដែលវិបត្តិនេះបង្ហាញឱ្យឃើញពីសារៈសំខាន់ក្នុងការធ្វើឱ្យទំនាក់ទំនងរវាងអ្នកបញ្ជាទិញ និងអ្នកផ្គត់ផ្គង់មានភាពរឹងមាំ ក៏ដូចជាសារៈសំខាន់ដើម្បីមានកិច្ចខិតខំរួមគ្នាក្នុងឧស្សាហកម្ម ឱ្យលក្ខខណ្ឌការងារ ផលិតភាព ហើយស្ថានភាពជារួមរបស់ឧស្សាហកម្មប្រសើរឡើង។

ការចូលរួមរបស់តំណាងអ្នកបញ្ជាទិញប្រចាំតំបន់ ជាប្រការមួយយ៉ាងសំខាន់ក្នុងវេទិកាឆ្នាំនេះ ក្នុងពេលដែលការសម្រេចចិត្តដើម្បីកម៉ង់ផលិតផលស្ថិតលើការសំរេចចិត្តរបស់ក្រុមហ៊ុនអាណាព្យាបាល។ ដូចគ្នានេះដែរ វាមានសារៈសំខាន់ក្នុងការធ្វើឱ្យតំណាងផ្នែកអ្នកបញ្ជាទិញមានការពាក់ព័ន្ធជាមួយដោយសារតែអ្នកបញ្ជាទិញកំពុងតែផ្លាស់ប្តូរទៅយុទ្ធសាស្ត្របញ្ជាទិញរួមមួយនៅពេលដែល តំលៃ គុណភាព រយៈពេលផ្គត់ផ្គង់ និងលក្ខខណ្ឌការងារត្រូវបានយកមកពិចារណា ក្នុងការសម្រេចផ្តល់ការបញ្ជាទិញទៅឱ្យរោងចក្រណាមួយ។

មួយផ្នែកធំនៃការពិភាក្សា ផ្តោតលើភាពព្យាយាមជាចាំបាច់ ដើម្បីបញ្ចៀសពីផលប៉ះពាល់ផ្នែកសង្គម និងហិរញ្ញវត្ថុលើវិបត្តិបច្ចុប្បន្ន។ អ្នកបញ្ជាទិញចង់ផ្ញើសារយ៉ាងច្បាស់លាស់មួយដល់អ្នកផ្គត់ផ្គង់ទាំងអស់ថា ពួកគេចង់ឱ្យរោងចក្រទាំងឡាយដែលឈប់ដំណើរការ ត្រូវបិទរោងចក្រដោយមានភាពទទួលខុសត្រូវ និងស្របតាមច្បាប់។

អ្នកបញ្ជាទិញខ្លះ ឈានដល់និយាយថា ពួកគេនឹងមិនបន្តទិញពីរោងចក្រ ឬអ្នកលក់ណាដែលមិនគោរពតាមគោលការណ៍នេះឡើយ។

ក្នុងកំឡុងថ្ងៃទី ២ *រោងចក្រកាន់តែប្រសើរ* និង *ការងារកាន់តែប្រសើរ* ជាមួយនឹងមូលនិធិអភិវឌ្ឍន៍វិស័យឯកជនតំបន់មេគង្គនៃសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ បានបង្ហាញដល់ក្រុមអ្នកបញ្ជាទិញនូវគំនិតផ្តួចផ្តើមថ្មីមួយ អំពីការអភិវឌ្ឍន៍ការអនុលោមទៅតាមបរិស្ថាន ការប្រើប្រាស់ថាមពលឱ្យមានប្រសិទ្ធិភាព និងសន្សំសំចៃរបស់កម្មវិធី។ គំនិតផ្តួចផ្តើមនេះ ត្រូវបានសាទរដោយអ្នកបញ្ជាទិញថា ជាទិសដៅដ៏ល្អបំផុតដែលកម្មវិធីឆ្ពោះទៅរក ដោយសារតែវាអាចជួយកាត់បន្ថយការធ្វើសវនកម្មច្រើនដង ដោយផ្តល់នូវសេវាកម្មបរិស្ថានថ្មីដែលជាចំនុចមួយដែលអ្នកបញ្ជាទិញចាប់អារម្មណ៍។ អង្គការពលកម្មអន្តរជាតិ និងសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិកំពុងធ្វើការជាមួយគ្នា ដើម្បីសម្ពោធគំរោងសាកល្បងមួយផ្តោតលើការប្រើប្រាស់ថាមពលឱ្យមានប្រសិទ្ធិភាព និងសន្សំសំចៃការចំណាយក្នុងពេលខាងមុខនេះ។

# វិបត្តិហិរញ្ញវត្ថុសកល មានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ...

តមកពីទំព័រទី ១



*កម្មករនិយោជិតរោងចក្របញ្ចៀតគ្នាចេញបន្ទាប់ពីធ្វើការងាររយូរម៉ោងរួចមក*

កំពុងស្ថិតនៅក្រោមការគំរាមកំហែង។ មានរោងចក្រជាង ៧០ បានបិទទ្វារ ហើយរោងចក្រដទៃទៀតកំពុងដំណើរការតែមួយភាគប៉ុណ្ណោះនៃសមត្ថភាពផលិតរបស់ខ្លួន។

ស្ថានភាពបែបនេះ បានធ្វើឱ្យអ្នកវិភាគមានការព្រួយបារម្ភថា ប្រជាជនកម្ពុជាជាច្រើននាក់ នឹងធ្លាក់ចូលទៅក្រោមបន្ទាត់នៃភាពក្រីក្រវិញ។ ការបញ្ជូនប្រាក់របស់កម្មករនិយោជិតរោងចក្រកាត់ដេរទៅកាន់គ្រួសារនៅជនបទ ទំនងជានឹងលែងមានតទៅទៀត ដែលជាហេតុធ្វើឱ្យគ្រួសារនៅជនបទរស់នៅដោយគ្មានធនធានក្នុងស្ថានភាពដ៏សែនលំបាក។ ឥឡូវនេះ កម្មករនិយោជិតរោងចក្រកំពុងចាប់ផ្តើមមានការព្រួយបារម្ភ។ ពួកគេបារម្ភថា គ្រួសាររបស់ពួកគេនឹងមិនអាចរស់បានឡើយ ប្រសិនបើគ្មានប្រាក់ដែលពួកគេផ្ញើទៅផ្ទះ។ មានពាក្យចចាមអារ៉ាមផ្សព្វផ្សាយពីការបិទរោងចក្រ និងការផ្អាកផលិតកម្មដែលធ្វើឱ្យកម្មករនិយោជិតមានការភ័យខ្លាចចំពោះអនាគត និងជម្រើសការងាររបស់ពួកគេ។ លោក អាត់ ធន់ ដែលជាប្រធានសហភាពការងារកម្ពុជាបានបញ្ជាក់ថា កម្មករនិយោជិតជាច្រើននាក់ កំពុងបាត់បង់ការងារដោយមិនបានទទួលសំណង ឬទទួលបានសំណងតិចតួចបំផុតពីនិយោជក ហើយជាទូទៅកំពុងមានភាពអស់សង្ឃឹមលើការងារនៅក្នុងឧស្សាហកម្មនេះ។

កញ្ញា ចាន់ សំណាង ជាកម្មការនីកាត់ដេរដែលមានអាយុ ២១ ឆ្នាំ និងធ្វើការងារនៅខណ្ឌឫស្សីកែវ ក្រុងភ្នំពេញ បាននិយាយថា និយោជិតទាំងអស់នៅក្នុងរោងចក្ររបស់នាងកំពុងចាប់ផ្តើមភ័យ។ ពួកគេឮរឿងរ៉ាវបញ្ឈប់កម្មករដោយគ្មានប្រាក់សំណងនៅតាមរោងចក្រដទៃទៀត ហើយពួកគេមិនដឹងព័ត៌មានអំពីអនាគតនៃការងាររបស់ពួកគេឡើយ។

លោក ស្តេហ្វាន ហ្គីមបើត មានប្រសាសន៍ថា វិស័យកសិកម្មនឹងមានតួនាទីជាសំណាញ់សុវត្ថិភាព បើទោះបីជាកម្មករនិយោជិតកាត់ដេរជាច្រើននាក់ស្ទាក់ស្ទើរមិនចង់ត្រឡប់ទៅទីជនបទ និងចង់បន្តស្នាក់នៅក្នុងទីក្រុងដែលទីផ្សារការងារកំពុងរួមតូច ហើយការងារកាន់តែមានតិចទៅៗក៏ដោយ។ ចាន់ សំណាង និយាយថា នាងនឹងធ្វើអ្វីៗគ្រប់បែបយ៉ាង ដើម្បីបន្តរស់នៅក្នុងក្រុងភ្នំពេញ។ នាងគិតថា នាងអាចរកលុយបានច្រើននៅទីក្រុង ហើយជីវិតមិនសូវជាពិបាកខ្លាំង។ ប៉ុន្តែ ជម្រើសការងារមានភាពប្រថុយប្រថានខ្លាំង : ជារឿយៗ ស្ត្រីដែលមិនអាចរកការងារធ្វើបាន គឺអាចធ្វើការងារជាស្រីលក់ស្រាបៀរ ឬធ្លាក់ចូលទៅក្នុងអាជីវកម្មផ្លូវភេទ។

លោក អាត់ ធន់ ឯកភាពថា កម្មករនិយោជិតមួយចំនួននឹងត្រឡប់ទៅភូមិកំណើតរបស់ពួកគេវិញ ហើយមួយចំនួនទៀតនឹងអាចរកការងារបានធ្វើនៅតាមអាជីវកម្មតូចៗជាលក្ខណៈគ្រួសារតាមផ្ទះ ជាពិសេស របរលក់ដូរបន្តិចបន្តួច។ គាត់ជឿជាក់ថា នេះជាពេលដែលរដ្ឋាភិបាលត្រូវមានអាទិភាពលើកទឹកចិត្តឱ្យមានការបង្កើតសហគ្រាសតូចៗទាំងនេះ និងធានាឱ្យកម្មករនិយោជិតជាច្រើននាក់ថែមទៀតអាចរកការងារបានធ្វើ នៅតាមអាជីវកម្មតូចៗ ដើម្បីកាត់បន្ថយគ្រោះថ្នាក់ដែលថាគ្រួសារនៅតាមទីជនបទនឹងធ្លាក់ខ្លួនក្រតោកយ៉ាក ឬ កម្មករនិយោជិតនឹងត្រូវបង្ខំចិត្ត ជ្រើសយកជម្រើសដែលប្រថុយប្រថាន ដោយសារតែការបាត់បង់ការងារ។

លោក កង ចាន់ដារ៉ារ័ត្ន នាយកវិទ្យាស្ថានកម្ពុជាដើម្បីសិក្សាការអភិវឌ្ឍន៍ (CIDS) កត់សម្គាល់ថា អ្វីៗអាចមានភាពល្អប្រសើរជាងមុន ដោយសារតែមានការខិតខំស្វែងរកទីផ្សារថ្មីៗ នៅតាមប្រទេសមួយចំនួនដូចជា រុស្ស៊ី ជប៉ុន និងមជ្ឈិមបូព៌ា។ ប៉ុន្តែការប្រឹងប្រែងទាំងនេះ ត្រូវការពេលវេលា ហើយពេលវេលាមិនមែនជាអ្វីដែលមាននៅក្នុងវិធានការធំៗ នាពេលបច្ចុប្បន្ននេះឡើយ។

សមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GMAC) ក៏គិតថា ស្ថានភាពលំបាកនឹងកើតមាននាពេលខាងមុខនេះ ប្រសិនបើការធ្លាក់ចុះសេដ្ឋកិច្ចមិនទាន់ចប់ទេនោះ។ លោក កាំង ម៉ូនីកា ដែលជាអ្នកគ្រប់គ្រងទំនាក់ទំនងកិច្ចការសាធារណៈរបស់ GMAC បានប្រាប់កាសែតឌីភ្នំពេញប៉ុស្តិ៍ (The Phnom Penh Post) កាលពីពេលថ្មីៗនេះថា អ្វីៗអាចមានភាពប្រសើរឡើងនៅក្នុងឆ្នាំ ២០០៩ ហើយមានសញ្ញាខ្លះចំពោះការងើបឡើងនូវសេដ្ឋកិច្ច និងការបញ្ជាទិញនឹងមានវិញម្តងទៀត។ អ្នកបញ្ជាទិញជាច្រើនដែល *គំរោងរោងចក្រកាន់តែប្រសើរ* បានទាក់ទងនៅតែមានជំនឿចិត្តកម៉ង់ទិញផលិតផលសំលៀកបំពាក់ពីប្រទេសកម្ពុជា ហើយរំពឹងថាអ្វីៗនឹងប្រសើរឡើងនាពេលអនាគតទោះបីជាពេលនេះកំពុងជួបនូវវិបត្តិក៏ដោយ។

ខណៈពេលផលប៉ះពាល់ពីវិបត្តិនេះ លេចចេញកាន់តែច្បាស់កម្មវិធី *រោងចក្រកាន់តែប្រសើរ* ប្រឹងប្រែងធ្វើការជាមួយដៃគូទាំងអស់ដើម្បីជួយនិយោជក និងនិយោជិតឱ្យរួចពីផលប៉ះពាល់ជាអវិជ្ជមាននៃការធ្លាក់ចុះសេដ្ឋកិច្ច និងជួយកសាងទំនុកចិត្តក្នុងឧស្សាហកម្មនេះទៅថ្ងៃអនាគត។

# ផែនការសកម្មភាពសម្រាប់ប្រទេសកម្ពុជា :...

តមកពីទំព័រទី ១

កំណត់ពីវិស័យដែលអង្គការពលកម្មអន្តរជាតិអាចជួយបាន សំដៅកាត់បន្ថយផលប៉ះពាល់មកលើសង្គមដោយសារវិបត្តិនេះ។ ការពិភាក្សាទាំងនេះបានបង្កើតឱ្យមានជាផែនការសកម្មភាពរបស់អង្គការពលកម្មអន្តរជាតិសម្រាប់ប្រទេសកម្ពុជា សកម្មភាពរយៈពេលខ្លីបន្ថែមលើការងារដែលកំពុងបន្តធ្វើរបស់អង្គការពលកម្មអន្តរជាតិក្រោមកម្មវិធីការងារសមរម្យ សម្រាប់ប្រទេសកម្ពុជា។ ផែនការនេះមាន ៣ សមាសធាតុធំៗ :

**ការឆ្លើយតបទៅនឹងវិបត្តិ នៅក្នុងវិស័យកាត់ដេរ :**

សមាសធាតុនេះ រួមមាន :

- វាយតំលៃផលប៉ះពាល់ ដែលវិបត្តិនេះមានមកលើកម្មករនិយោជិតវិស័យកាត់ដេរ
- ផ្តល់ជំនួយ សម្រាប់ការគ្រប់គ្រងការបញ្ឈប់ការងារកម្មករនិយោជិតប្រកបដោយការទទួលខុសត្រូវ (តាមរយៈការបង្កើតឱ្យមាន «ទីប្រឹក្សាអន្តរកាលសម្រាប់ការទទួលខុសត្រូវសង្គម»)
- កសាងទំនុកចិត្តមកលើអនាគតរបស់ឧស្សាហកម្មនេះ និងការបណ្តុះបណ្តាលជំនាញគោលដៅ (ដូចជាការបញ្ជូនកម្មករនិយោជិតដែលបាត់បង់ការងារ និងយុទ្ធនាការលើកកំពស់មុខមាត់របស់ឧស្សាហកម្ម)។
- កាត់បន្ថយការខាតបង់នៃការវិនិយោគ និងជម្រើសជីវភាពរបស់កម្មករនិយោជិត (ឧទាហរណ៍ តាមរយៈការផ្តល់ប្រាក់កម្ចី និង ការបណ្តុះបណ្តាល) និង
- កាត់បន្ថយភាពងាយរងគ្រោះនៃសុខភាពរបស់មាតា និងបង្កើនការទទួលបានការថែទាំសុខភាព

**គំរោងហេដ្ឋារចនាសម្ព័ន្ធ ដែលបង្កើតការងារច្រើន (EIIP) :**

ផ្អែកលើសារៈសំខាន់នៃតួនាទីរបស់ការងារ ដែលមិនត្រឹមតែអាចបង្កើតការងារ និងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធដែលចាំបាច់ខ្លាំងផងនោះ អង្គការពលកម្មអន្តរជាតិ នឹងតែងតាំងអ្នកជំនាញអន្តរជាតិខាង EIIP មួយរូបនៅក្នុងប្រទេសកម្ពុជា ដើម្បីបង្កើតយុទ្ធសាស្ត្រ ឆ្លើយតបទៅនឹងវិបត្តិនេះ។ អង្គការពលកម្មអន្តរជាតិបាន និងកំពុងធ្វើការងារ EIIP ក្នុងប្រទេសកម្ពុជា តាំងពីឆ្នាំ ១៩៩២ មកម្ល៉េះ។

**ជំនាញ និងការបណ្តុះបណ្តាល**

អង្គការពលកម្មអន្តរជាតិ បានឯកភាពជាមួយនឹងរាជរដ្ឋាភិបាល ដើម្បីផ្តល់ជំនួយដល់ការអនុវត្តកម្មវិធីដែលបានគ្រោងទុក ដើម្បីផ្តល់ជំនាញ និងការបណ្តុះបណ្តាលដល់កម្មករនិយោជិត ដែលបាត់បង់ការងារ ដូចជាការបង្កើតមជ្ឈមណ្ឌលអប់រំបច្ចេកទេស និង វិជ្ជាជីវៈ (TVET) និង មជ្ឈមណ្ឌលការងារតំបន់។ ចំពោះការងារនេះ អង្គការពលកម្មអន្តរជាតិនឹងជ្រើសរើសអ្នកជំនាញជនជាតិខ្មែរមួយរូប ដើម្បីផ្តល់ការបណ្តុះបណ្តាលដល់ក្រុមអ្នកវាយតំលៃឱ្យចេះវាយតំលៃតម្រូវការរបស់កម្មករនិយោជិតនៅតាមតំបន់នានា និងតែងតាំងអ្នកជំនាញដែលមានសមត្ថភាពមួយរូបឱ្យធ្វើការងារជាមួយនឹងក្រសួងការងារដើម្បីគាំទ្រដល់ការធ្វើផែនការ និងការអនុវត្តន៍មជ្ឈមណ្ឌលការងារ។

ផែនការសកម្មភាពនេះ ក៏មានសមាសធាតុតូចៗ ៣ ទៀត ដែលនឹងពិនិត្យលើចំនុចដូចខាងក្រោម :

- ផលប៉ះពាល់មកលើការអប់រំ និងពលកម្មកុមារ
- ផលប៉ះពាល់មកលើមុខរបរ និងចំណាកស្រុក និង
- ស្ថិតិទីផ្សារការងារ (គាំទ្រដល់វិទ្យាស្ថានជាតិស្ថិតិ (NIS) ឱ្យបង្កើតការអង្កេតអំពីកម្លាំងពលកម្ម ២០០៩,២០១០)។

ពិធីដែលបានប្រារព្ធឡើង នៅថ្ងៃទី ២៧ និង ២៨ ខែ មេសា មានការចូលរួមពីលោកជំទាវ ម៉ែន សំអន ឧបនាយករដ្ឋមន្ត្រី និងជាតំណាងរបស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន និង មានការថ្លែងសន្ទរកថាកម្រិតខ្ពស់របស់លោកស្រី សាជីកូ យ៉ាម៉ាម៉ូតុ (Sachiko Yamamoto) នាយិកាការិយាល័យអង្គការពលកម្មអន្តរជាតិ ប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក រួមទាំងឯកឧត្តម វង សូត រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ពិធីដែលមានរយៈពេល ២ ថ្ងៃនេះក៏មានការដាក់តាំងបង្ហាញរូបថតទាក់ទងនឹងការងាររបស់អង្គការពលកម្មអន្តរជាតិ ខ្សែភាពយន្តឯកសារ និង ពិពណ៌ផ្សេងទៀត សម្រាប់ទស្សនិកជន ដូចជាការតាំងបង្ហាញម៉ូដសំលៀកបំពាក់ និងអត្ថបទចំរៀងដែលទទួលបានជ័យលាភីពីការប្រកួតប្រជែង «ខ្ញុំមានតំលៃ»។

# កិច្ចប្រជុំតុមូលធុរកិច្ចរបស់អ្នកជំនាញសេដ្ឋកិច្ចជាមួយរាជរដ្ឋាភិបាល : ជិតទទួលបានលទ្ធផលថ្មី?

ដោយសារមានការចាប់អារម្មណ៍ពីសក្តានុពលធុរកិច្ចរបស់ប្រទេសកម្ពុជា សន្និសីទសេដ្ឋវិទូ ជាអង្គភាពធុរកិច្ចរបស់ទស្សនាវដ្តីសេដ្ឋវិទូ (The Economist) ដែលមានមូលដ្ឋាននៅចក្រភពអង់គ្លេស បានរៀបចំនូវកិច្ចប្រជុំតុមូលកម្រិតខ្ពស់មួយជាមួយរដ្ឋាភិបាលស្តីពីធុរកិច្ច និងការអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅទីក្រុងសៀមរាបកាលពីថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០៩ កន្លងទៅនេះ។ ប្រទេសកម្ពុជា មានកំណើនសេដ្ឋកិច្ចគួរឱ្យកត់សម្គាល់នៅក្នុងឆ្នាំថ្មីៗនេះ ហើយការវិលត្រឡប់មកវិញនូវស្ថិរភាពសង្គម បានត្រួសត្រាយផ្លូវឱ្យមានស្ថិរភាពនយោបាយល្អប្រសើរ និងសង្គមស៊ីវិលដែលរស់រវើក។ កត្តាទាំងនេះរួមផ្សំគ្នា មានន័យថាឥឡូវនេះ ប្រទេសកម្ពុជាជាទិសដៅវិនិយោគ និងធុរកិច្ចដ៏គួរឱ្យចាប់អារម្មណ៍មួយ។

សន្និសីទនេះ ប្រារព្ធឡើងចំពេលមានវិបត្តិហិរញ្ញវត្ថុសកល ដោយមានការចូលរួមពីតំណាងធុរកិច្ចក្នុងស្រុក មន្ត្រីរដ្ឋាភិបាល និងដៃគូវិនិយោគទុនជាច្រើននាក់ ដើម្បីពិភាក្សាគ្នាអំពីបញ្ហាប្រឈម និងកាលានុវត្តភាព ដែលប្រទេសកម្ពុជាកំពុងជួបប្រទះ។

សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានថ្លែងសន្ទរកថាជាទូទៅមួយស្តីពីសក្តានុពលសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ដោយសម្តេចបានគូសបញ្ជាក់ថា រដ្ឋាភិបាលមានគោលបំណងបន្តលើកកំពស់ការវិនិយោគ និងការបង្កើតការងារប្រកបដោយនិរន្តរភាព និងការទទួលខុសត្រូវ។ សម្តេចបានគូសបញ្ជាក់សារជាថ្មីថា រដ្ឋាភិបាលនឹងបន្តលើកកំពស់បរិយាកាសវិនិយោគទុនដែលមានលក្ខណៈអនុគ្រោះ ដែលនឹងបង្កលក្ខណៈឱ្យបន្តមានកំណើននៅក្នុងវិស័យកំណើនដែលមានស្រាប់ ដូចជាវិស័យកាត់ដេរ និងទេសចរណ៍ ប៉ុន្តែជាមួយគ្នានេះដែរ នឹងត្រួសត្រាយផ្លូវឱ្យកំណើនសេដ្ឋកិច្ចនាពេលអនាគតកើតចេញពីប្រភពសំបូរបែបផ្សេងពីគ្នា។ នៅពេលពិភាក្សាអំពីវិស័យកាត់ដេរ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានមានប្រសាសន៍ទៅកាន់អ្នកចូលរួមថា បទពិសោធន៍ទទួលបានពីឧស្សាហកម្មដ៏សំខាន់នេះ បានផ្តល់នូវមេរៀនគន្លឹះសម្រាប់ការអភិវឌ្ឍន៍វិស័យផលិតកម្មដទៃទៀត ហើយលក្ខខណ្ឌការងារល្អប្រសើរបានផ្តល់ឱ្យប្រទេសកម្ពុជានូវឧត្តមភាពប្រកួតប្រជែងមួយគួរឱ្យកត់សម្គាល់។ សម្តេចបានគូសបញ្ជាក់ពីគោលនយោបាយរបស់រដ្ឋាភិបាល សំដៅកាត់បន្ថយឧបសគ្គចំពោះការអភិវឌ្ឍន៍វិស័យឯកជន តាមរយៈការផ្តល់ជំនួយបន្ថែម និងការសំរួលនីតិវិធីរដ្ឋបាល។

ការធ្លាក់ចុះសេដ្ឋកិច្ចនាពេលបច្ចុប្បន្ន ក៏ត្រូវបានលើកយកមកពិភាក្សាផងដែរ ដោយគណៈវាគ្មិនដែលរួមមាន ឯកឧត្តម ប៉ាន សូរស័ក្តិ អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម លោក ជីម លឿង (Jim Leung) នាយកប្រចាំតំបន់របស់ក្រុមហ៊ុន Walt Disney និង លោក វ៉ាន់ ស៊ូអៀង ប្រធានសហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា (CAMFEBA)។ គណៈវាគ្មិនបានពិភាក្សាអំពីបញ្ហានាពេលបច្ចុប្បន្ន និង បញ្ហាដែលអាចកើតមានឡើងនាពេលអនាគត ពាក់ព័ន្ធនឹងវិស័យផលិតកម្មរបស់ប្រទេសកម្ពុជា។ គណៈវាគ្មិនបានសន្និដ្ឋានថា ខណៈពេលដែលវិបត្តិនេះមានផលប៉ះពាល់ធ្ងន់ធ្ងរ ក៏មានផងដែរនូវកាលានុវត្តភាពសម្រាប់ការធ្វើពាណិជ្ជកម្មរយៈពេលមធ្យម និង វែងនៅក្នុងប្រទេសកម្ពុជា ហើយនេះគឺជាពេលដែលប្រទេសកម្ពុជាត្រូវបង្ហាញពីគោលបំណងវិនិយោគរបស់ខ្លួននៅក្នុងវិស័យនានាជាច្រើន ដែលជាលក្ខខណ្ឌចាំបាច់សម្រាប់ទាក់ទាញវិនិយោគបន្ថែម ដូចជាការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ និងការផលិតអគ្គិសនីជាដើម។

នៅពេលនិយាយពីការប្តេជ្ញាចិត្តរបស់អ្នកបញ្ជាទិញសំលៀកបំពាក់អន្តរជាតិក្នុងការបន្តបញ្ជាទិញពីប្រទេសកម្ពុជា លោក លឿង មកពីក្រុមហ៊ុន Disney បានបង្ហាញពីទស្សនៈរបស់លោកថា មូលហេតុមួយក្នុងចំណោមមូលហេតុជាច្រើនដែលធ្វើឱ្យប្រទេសកម្ពុជាទទួលបានលទ្ធផលយ៉ាងល្អ នៅក្នុងឧស្សាហកម្មកាត់ដេររបស់ខ្លួន គឺការយកចិត្តទុកដាក់ចំពោះលក្ខខណ្ឌការងារតាមរយៈគំនិតផ្តួចផ្តើមនៃគំរោង *រោងចក្រកាន់តែប្រសើរនៅកម្ពុជា*។ ក្រុមហ៊ុនបញ្ជាទិញជាច្រើនដែលធ្លាប់មានការស្ទាក់ស្ទើរក្នុងការវិនិយោគក្នុងប្រទេសកម្ពុជា ឥឡូវនេះកំពុងវិនិយោគនៅក្នុងប្រទេសកម្ពុជា ដោយសារតែកិច្ចខិតខំប្រឹងប្រែងជាបន្តបន្ទាប់ដែលធ្វើឱ្យមានការរីកចំរើនគួរឱ្យកត់សម្គាល់កន្លងមក។

លោក ស្តេហ្វាន ហ្គីមបើត (Stéphane Guimbert) សេដ្ឋវិទូជាន់ខ្ពស់របស់ធនាគារពិភពលោកប្រចាំនៅប្រទេសកម្ពុជា លោក ប៊ីល សលធើ នាយកការិយាល័យអង្គការ ILO ប្រចាំអនុតំបន់អាស៊ីបូព៌ា និង លោក ឌូហ្គ្លាស ប្រូឌើរីក (Douglas Broderick) អ្នកសំរបសំរួលប្រចាំប្រទេសរបស់អង្គការសហប្រជាជាតិ បានបញ្ជាក់ឡើងវិញនៅក្នុងសន្និសីទនេះថា ការរីកចំរើនដ៏វិជ្ជមាននៃសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា គឺនៅមានភាពផុយស្រួយនៅឡើយ ហើយក្រុមភ្នាក់ងាររបស់អង្គការសហប្រជាជាតិជាមួយនឹងរដ្ឋាភិបាល កំពុងបន្តសហការគ្នាលើបញ្ហាជាច្រើន ដូចជាការទទួលបានការអប់រំសុខភាព និងការដាក់ឱ្យប្រើប្រាស់នូវបណ្តាញសុវត្ថិភាពសង្គមដើម្បីឱ្យស្ត្រី និងកុមារកម្ពុជាជាច្រើននាក់ទៀតមិនធ្លាក់ចូលទៅក្នុងភាពក្រីក្រ និងការអត់ឃ្លាន។

# កម្រងអត្ថបទស្តីពីប្រវត្តិអ្នកពាក់ព័ន្ធសំខាន់ៗក្នុងវិស័យឧស្សាហកម្មកាត់ដេរ

***នៅក្នុងកិច្ចខិតខំប្រឹងប្រែង ដើម្បីបង្កើនការយល់ដឹងកាន់តែប្រសើរទូទាំងឧស្សាហកម្ម រោងចក្រកាន់តែប្រសើរ ធ្វើការងារជាមួយនឹងអ្នកដែលមានការពាក់ព័ន្ធផ្សេងៗ ដើម្បីសំរបសំរួលឱ្យមានកិច្ចសន្ទនា និងការចរចាប្រកបដោយការគោរពគ្នាទៅវិញទៅមក។ កម្រងអត្ថបទថ្មីរបស់រោងចក្រកាន់តែប្រសើរនេះ នឹងបង្ហាញព័ត៌មានអំពីអ្នកដែលចូលរួមយ៉ាងសកម្មនៅក្នុងវិស័យកាត់ដេរ ផ្តល់ព័ត៌មានពីប្រវត្តិជាទូទៅ រៀបរាប់ពីគំនិតយោបល់ និងបំណងប្រាថ្នា ក៏ដូចជាស្វែងយល់ពីកត្តាប្រឈមមុខ និងអ្វីដែលលើកទឹកចិត្តឱ្យពួកគេបន្តការងារក្នុងវិស័យនេះ។***

**លី តេកហេង ប្រធានប្រតិបត្តិការរបស់សមាគមរោងចក្រកាត់ដេរនៅកម្ពុជា**

ដោយបានបំរើការងារ នៅក្នុងឧស្សាហកម្មកាត់ដេរ ជិតមួយទស្សវត្សរ៍រួចមក ឥឡូវនេះ លី តេកហេង គឺជាប្រធានប្រតិបត្តិការរបស់សមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GMAC)។ មុខតំណែងពីមុនរបស់លោក គឺជំនួយការអ្នកគ្រប់គ្រង ដែលពេលនោះលោកទទួលខុសត្រូវធ្វើការងារយ៉ាងជិតស្និទ្ធជាមួយនឹងអ្នកវិនិយោគទុនបរទេសក្នុងវិស័យកាត់ដេរ និងផ្តល់ព័ត៌មានអំពីការវិនិយោគទុន ច្បាប់ការងារ និង ដំបូន្មានដល់សមាជិករបស់ក្រុមប្រឹក្សាភិបាលប្រតិបត្តិរបស់ GMAC ដែលភាគច្រើនមកពីប្រទេសចិន ហុងកុង ម៉ាកាវ ម៉ាឡេស៊ី និងសឹង្ហបុរី។



*លោក លី តេកហេង ប្រធានប្រតិបត្តិការរបស់ GMAC*

តេកហេង កើតនៅក្នុងឆ្នាំ ១៩៧០ នៅក្នុងគ្រួសារអ្នកជំនួញធុនមធ្យមមួយ ហើយបានចំណាយវ័យកុមាររបស់គាត់នៅក្នុងរបបប្រល័យពូជសាសន៍។ គាត់ធំពេញវ័យ ក្នុងពេលដែលប្រទេសកម្ពុជានៅជាសមរភូមិនៅឡើយ ដោយសារតែការអូសបន្លាយសង្គ្រាមស៊ីវិល។

បន្ទាប់ពីការដួលរលំនៃរបបខ្មែរក្រហម តេកហេង និងគ្រួសាររបស់គាត់បានរស់នៅក្នុងខេត្តបាត់ដំបង ដែលនៅទីនោះ គាត់បានបញ្ចប់ការសិក្សាកម្រិតមធ្យមសិក្សា។ បន្ទាប់ពីបញ្ចប់ការសិក្សា លោកបានទៅជំរំជនភៀសខ្លួន SITE II ដែលមានទីតាំងនៅតាមព្រំដែនកម្ពុជា-ថៃ ដោយលោកសង្ឃឹមថានឹងអាចបន្តការសិក្សា អាចចូលរៀនភាសាអង់គ្លេសដោយមិនបង់ថ្លៃ និងទទួលបានជំនាញបណ្តុះបណ្តាលវិជ្ជាជីវៈមួយចំនួន : ជំរុំនេះទទួលបានការគាំទ្រពីសហគមន៍អន្តរជាតិ ហើយមានឱកាសជាច្រើនដើម្បីឱ្យអ្នកដែលចង់រៀនសូត្រដូចជា តេកហេង អាចរស់នៅទីនោះ និងរៀនសូត្រពីបុគ្គលិកបរទេសដែលមកជួយជនភៀសខ្លួននៅក្នុងជំរុំ។ លោកបានរស់នៅក្នុងជំរុំនោះរហូតដល់មានកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ដែលអនុញ្ញាតឱ្យជនភៀសខ្លួនកម្ពុជាពីគ្រប់និន្នាការនយោបាយអាចវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញបាន និងឱ្យមានការបោះឆ្នោតប្រជាធិបតេយ្យលើកដំបូង ដែលរៀបចំឡើងដោយអង្គការសហប្រជាជាតិនៅក្នុងឆ្នាំ ១៩៩៣។

នៅក្នុងឆ្នាំ ១៩៩៣ តេកហេង បានទទួលអាហារូបករណ៍ពីរដ្ឋាភិបាលដើម្បីសិក្សាភាសាអង់គ្លេសនៅមជ្ឈមណ្ឌលភាសាអន្តរជាតិ ដែលឥឡូវនេះក្លាយជាវិទ្យាស្ថានភាសាបរទេសនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ ៤ ឆ្នាំក្រោយមក លោកទទួលបានបរិញ្ញាបត្រ ហើយបានបំរើការងារនៅសាលាណសប្រីជអន្តរជាតិ រយៈពេល ២ ឆ្នាំ។

តេកហេង មិនដែលធ្លាប់គិតថានឹងធ្វើការងារនៅក្នុងឧស្សាហកម្មកាត់ដេរឡើយ ដោយសារតែមានការយល់ឃើញជាទូទៅថា វិស័យនេះមិនផ្តល់បៀវត្សរ៍ច្រើន និងមានព័ត៌មានអំពីការរំលោភបំពានសិទ្ធិរបស់កម្មករនិយោជិត លក្ខខណ្ឌការងារមិនល្អ និងកូដកម្មខុសច្បាប់ ចុះផ្សាយលើទំព័រមុខរបស់កាសែតក្នុងស្រុក។ ប៉ុន្តែពេលនោះ លោកចង់ដឹងអំពីអ្វីដែលកំពុងកើតមានឡើងនៅក្នុងវិស័យនេះ ដូច្នេះ បើទោះបីជាមានការស្ទាក់ស្ទើរពីដំបូងក៏ដោយ ក៏លោកបានសម្រេចចិត្តធ្វើការងារជាអ្នកបកប្រែភាសាឱ្យ GMAC នៅក្នុងឆ្នាំ ១៩៩៩ ហើយក្រោយមកឡើងឋានៈជាអ្នកគ្រប់គ្រងការិយាល័យ។

ការធ្វើការងារនៅ GMAC បានផ្តល់ឱកាសឱ្យលោកយល់ឃើញថា វិវាទដែលធ្វើឱ្យមានកូដកម្មនៅតាមរោងចក្រកាត់ដេរ អាចកើតឡើងដោយសារភាគីទាំងសងខាង គឺនិយោជក ឬ និយោជិត។ លោកបាននិយាយថា ការយល់ជាទូទៅថា វិវាទកើតមានឡើងដោយសារតែនិយោជកប្រើអំណាចដោយបំពានលើនិយោជិត គឺជាការយល់ខុសមួយ។ តេកហេង បញ្ជាក់ថា លោកមានការយល់ឃើញបែបនេះបន្តិចម្តងៗ មិនមែនដោយសារតែលោកធ្វើការនៅ GMAC នោះទេ ប៉ុន្តែដោយសារតែសមាគមនេះ ជានិច្ចជាកាលតែងតែខិតខំដោះស្រាយវិវាទរវាងនិយោជក និងនិយោជិត ដោយផ្អែកលើមូលដ្ឋានច្បាប់ការងារដែលមានស្រាប់របស់ប្រទេសកម្ពុជា។

លោក តេកហេង បានលើកឡើងថា លក្ខខណ្ឌការងារ និងទំនាក់ទំនងវិជ្ជាជីវៈនៅក្នុងឧស្សាហកម្មកាត់ដេរ មានការកែលំអយ៉ាងច្រើន បើប្រៀបនឹងកាលពីមុន។ លោកជឿជាក់ថា វិវាទការងារ គឺមិនអាចចៀសរួចបានឡើយ ដោយសារតែវិស័យកាត់ដេរ ជាវិស័យដែលមានកម្លាំងពលកម្មច្រើនជាងគេ ហើយជាឧស្សាហកម្មអាទិភាពរបស់ប្រទេសកម្ពុជា។ លោកគូសបញ្ជាក់ថា ការមានសហជីពមូលដ្ឋាននៅតាមរោងចក្រធ្វើឱ្យវិវាទទាំងឡាយងាយស្រួលដោះស្រាយ ដោយសារតែសហជីពទាំងនោះអាចតំណាងឱ្យសេចក្តីត្រូវការរបស់កម្មករនិយោជិតទាំងអស់។ យ៉ាងណាក៏ដោយ ការមានសហជីពច្រើនក៏អាចបង្កើតឱ្យមានបញ្ហាលំបាកផងដែរនៅពេលខិតខំស្វែងរកការសម្រុះសម្រួលមួយ ដោយសារតែសហជីពទាំងនោះមានតម្រូវការច្រើន និងផ្សេងៗពីគ្នា។

តេកហេង លើកឡើងពីតម្រូវការកសាងសមត្ថភាព សម្រាប់និស្សិតខ្មែរវ័យក្មេង ដើម្បីឱ្យពួកគេអាចកាន់តំណែងជាអ្នកគ្រប់គ្រងនៅក្នុងរោងចក្រ ដោយសារតែកម្មករនិយោជិតភាគច្រើនទទួលបានការអប់រំតិចតួច។ កន្លងមកមានវិទ្យាស្ថានក្នុងស្រុកដែលផ្តល់ការបណ្តុះបណ្តាលដល់កម្មករនិយោជិតកាត់ដេរអំពីការជួសជុលម៉ាស៊ីនដេរ ការដេរ ការត្រួតពិនិត្យគុណភាព និងជំនាញមេការ។ តេកហេង មើលឃើញអត្ថប្រយោជន៍ ២ យ៉ាងនៅពេលមានជនជាតិខ្មែរធ្វើការងារជាអ្នកគ្រប់គ្រងពីថ្នាក់កណ្តាលដល់ថ្នាក់ខ្ពស់។ ទី ១ រោងចក្រ នឹងអាចសន្សំថវិកាបានច្រើន ដោយសារតែពួកគេមិនចាំបាច់ចំណាយលើការស្នាក់នៅ និងការធ្វើដំណើរ ហើយមិនចាំបាច់ចំណាយបៀវត្សរ៍ខ្ពស់សម្រាប់អ្នកជំនាញការបរទេស។ ទី ២ វិវាទនៅក្នុងកន្លែងធ្វើការនឹងថយចុះតិចជាងមុន ដោយសារតែវិវាទជាច្រើនកើតឡើងដោយសារតែវប្បធម៌ខុសគ្នា និងឧបសគ្គភាសារវាងកម្មករនិយោជិត និងអ្នកគ្រប់គ្រងបរទេស។

**មាស មរកត សហព័ន្ធសាមគ្គីភាព ឯករាជ្យ និងប្រជាធិបតេយ្យ (DISUF)**

មាស មរកត មានអាយុ ៣៩ ឆ្នាំ។ នៅក្នុងឆ្នាំ១៩៨០ នៅពេលដែលរបបប៉ុលពតផុតរលត់ទៅ គ្រួសាររបស់នាងបានវិលត្រឡប់មកក្រុងភ្នំពេញវិញ ហើយនាងបានចូលរៀនសាលាបឋមសិក្សា។ នាងចង់បន្តសិក្សា ប៉ុន្តែ គ្រួសាររបស់នាងមិនមានប្រាក់គ្រប់គ្រាន់។ នាងធ្វើការដំបូងនៅពេលដែលមានអាយុ ១៧ ឆ្នាំ : នាងចង់ធ្វើការ និងរកលុយខ្លះសម្រាប់គ្រួសារ។ នៅក្នុង ឆ្នាំ ១៩៩២ នាងបានចូលធ្វើការងារនៅក្នុងរោងចក្រមួយ។ នាងធ្វើការងារផ្នែកកាត់ និងបង្ហើយការក្តារឈើរយៈពេល ៧ ឆ្នាំ។ ការងារនេះ គឺជាការងារគ្រោះថ្នាក់ ហើយរណាមានទំងន់ធ្ងន់ខ្លាំង។ ក្នុងពេលនោះ នាងបានរៀបការ និងមានកូនដំបូង។



*លោកស្រី មាស មរកត អនុប្រធាន DISUF*

នៅក្នុងឆ្នាំ ១៩៩៩ មាស មរកត ត្រូវបានរោងចក្រកាត់ដេរមួយជួលឱ្យធ្វើការ។ បច្ចុប្បន្ននេះ នាងនៅតែធ្វើការងារនៅក្នុងរោងចក្រនេះ។ នៅពេលដែលនាងទើបចូលធ្វើការដំបូង លក្ខខណ្ឌការងារ និងទំនាក់ទំនងរវាងនិយោជិត និងនិយោជកមានភាពអន់ខ្សោយខ្លាំង។ និយោជកធ្វើខុសច្បាប់ជាបន្តបន្ទាប់ និងបង្ខំកម្មករនិយោជិត ឱ្យធ្វើការបន្ថែមម៉ោង។ និយោជកក៏បណ្តេញកម្មករនិយោជិតពីការងារ ឬ កាត់ប្រាក់ឈ្នួលរបស់ពួកគេផងដែរប្រសិនបើគាត់គិតថាពួកគេឈឺធ្ងន់ ឬ ខ្សោយខ្លាំង។

បន្ទាប់ពីនាងបានធ្វើការទីនោះបានប្រហែលជា ១ ឆ្នាំមក មជ្ឈមណ្ឌលអាមេរិកសម្រាប់សាមគ្គីភាពការងារអន្តរជាតិ (ACILS) បានចុះទៅកាន់រោងចក្រនោះ និងសាកសួរនិយោជិតអំពីលក្ខខណ្ឌការងារនៅក្នុងរោងចក្រ។ កម្មករនិយោជិតបានប្រាប់គេថា ពួកគេចង់បង្កើតសហជីព ប៉ុន្តែពួកគេមិនហ៊ាន។ ACILS បានប្រាប់ពួកគេថា ច្បាប់នឹងការពារពួកគេ ដូច្នេះនៅចុងឆ្នាំ ២០០០ មាស មរកត បានធ្វើសកម្មភាពចងក្រង និងប្រមូលមិត្តរួមការងាររបស់នាង ហើយពួកគេបានរៀបចំការបោះឆ្នោត និងបានបង្កើតសហជីពមួយដែលជាសមាជិករបស់សហព័ន្ធសាមគ្គីភាព ឯករាជ្យ និងប្រជាធិបតេយ្យ (DISUF)។ នាងត្រូវបានគេបោះឆ្នោតឱ្យធ្វើជាប្រធានសហជីពឈ្នះបេក្ខជនបុរសជាច្រើននាក់។ គ្រប់មុខតំណែងកំពូលៗទាំងអស់ក្នុងសហជីពនេះគឺស្ត្រីជាអ្នកកាន់កាប់។

មាស មរកត ចូលរួមក្នុងការងារសហជីព ដោយសារតែនាងចង់ឱ្យមានការផ្លាស់ប្តូរ។ នាងចង់ជួយខ្លួនឯង ប៉ុន្តែគំនិតដំបូងរបស់នាង គឺចង់ជួយកម្មករនិយោជិត : នាងជឿជាក់ថា នេះគឺជាមូលហេតុដែលនាងជាប់ឆ្នោតធ្វើជាប្រធានសហជីព។ ប៉ុន្តែ និយោជកបដិសេធមិនទទួលស្គាល់សហជីពនេះ ហើយមិនចង់ចរចា។ គាត់រើសអើងសមាជិកសហជីព ហើយប្រើប្រាស់អំណាចរបស់គាត់ដើម្បីរារាំងកម្មករនិយោជិតដទៃទៀតមិនឱ្យចូលរួម ហើយថែមទាំងបញ្ឈប់ការងារសមាជិកសហជីពមួយចំនួនទៀតផង។ សហជីពបានប្តឹងទៅក្រសួងការងារ ហើយយកករណីនេះទៅកាន់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទាមទារឱ្យនិយោជកទទួលយកនិយោជិតទាំងនេះឱ្យចូលធ្វើការវិញ និងទទួលស្គាល់សហជីពនេះជាផ្លូវការ។

សហជីពបានសម្រេចចិត្តថា ការធ្វើកូដកម្ម គឺជាជម្រើសចុងក្រោយតែមួយគត់ ហើយនិយោជកក៏យល់ព្រមចរចា។ រហូតមកដល់ពេលបច្ចុប្បន្ន សហជីពបានទទួលជោគជ័យជាច្រើននៅក្នុងការបង្កើតឱ្យមានបរិយាកាសការងារល្អប្រសើរជាងមុន ហើយទំនាក់ទំនងរវាងកម្មករនិយោជិត និងនិយោជកមានភាពល្អប្រសើរជាងមុនយ៉ាងច្រើន។

បច្ចុប្បន្ន មាស មរកត គឺជាអនុប្រធាន DISUF ហើយនាងក៏ធ្វើការងារជាអ្នកអប់រំសហជីពផងដែរ។ ការងារនេះគឺជាការងារលំបាក និង ពោរពេញទៅដោយភាពតានតឹង ហើយនាងចង់បណ្តុះបណ្តាលមនុស្សដទៃទៀតឱ្យបន្តការងារនេះ។ នាងក៏បានក្លាយជាលេខារបស់អង្គការចលនាស្ត្រីកម្ពុជា (CWMO) ផងដែរ ហើយគឺជាអ្នកដឹកនាំសហគមន៍របស់នាងទៀតផង។

មាស មរកត មានមោទនភាពយ៉ាងខ្លាំងចំពោះការវិវត្តន៍របស់នាងពីកម្មករនិយោជិតរោងចក្រមកជាអ្នកដឹកនាំសហគមន៍ និង ជាប្រធានសហជីព។ នាពេលអនាគត នាងចង់ឃើញសហជីពតូចៗ នៅក្នុងប្រទេសកម្ពុជាកាត់ផ្តាច់ចំណងនយោបាយ និងរួមគ្នាជាធ្លុងមួយ ដើម្បីបង្កើតសហព័ន្ធធំមួយ។ នាងនិយាយថា ជាមួយសំលេងតែមួយ កម្មករនិយោជិតនឹងមានអំណាចច្រើនថែមទៀត ដើម្បីបង្កើតលក្ខខណ្ឌការងារល្អប្រសើរ និងធានាថាកម្មករនិយោជិតទទួលបានប្រាក់ឈ្នួលសមរម្យដែលអាចឱ្យពួកគេមានជីវភាពល្អប្រសើរបាន។